# Criminal Liability of Legal Person (Cambodian Criminal Code)

នៅក្រុមកម្ពុជា មានក្រុមហ៊ុនអាជីវកម្ម ដែលចុះបញ្ជី ដែលជានីតិបុគ្គល។ ការធ្វើអាជីវកម្មស្វែងរកផលចំណេញ អាចប៉ះពាល់ ដែលជាទង្វើចែងហាមឃាត់ដោយច្បាប់ នាំឲ្យនីតិបុគ្គលទទួលខុសត្រូវ។ តើច្បាប់ និងបទប្បញ្ញត្តិកម្ពុជា បានចែងអ្វីខ្លះពាក់ព័ន្ធនឹង ការទទួលខុសត្រូវរបស់នីតិបុគ្គល។

<u>មាត្រា ៤២</u> ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

*នៅក្នុងករណីដែលមានចែងដាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។*

*ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ ។*

១. នីតិបុគ្គល (ក្រុមហ៊ុន ឯកជន មិនមែនរដ្ឋ) លុះត្រាមានច្បាប់ចែងឲ្យទទួលខុសត្រូវ។ ២. អ្នកតំណាង ឬអង្គការ (មិនមែនបុគ្គលសាមញ្ញទេ)។ ៣. ដើម្បីប្រយោជន៍ (ប្រទេសគេ ក្នុងម៉ោងការងារ) ។ ៤. ទង្វើអ្នកតំណាង (បុគ្គល) ដើម្បីផលប្រយោជន៍ នីតិបុគ្គល (មិនបានចែងពេលណា) នីតិបុគ្គលក៏ទទួលខុសត្រូវ ហើយអ្នកតំណាងក៏ទទួលខុសត្រូវដែរ។ ៥. ច្បាប់មិនបានចែង តែដើម្បីឲ្យទទួលខុសត្រូវ ត្រូវបង្ហាញបទល្មើសប្រព្រឹត្ត ដោយតំណាង ដើម្បីប្រយោជន៍ និង មានការចូលរួមរបស់នីតិបុគ្គល (ធ្វេសប្រហែសមិនណែនាំជាដើម)។ ៦. ដោយសារគេមិនអាចដាក់គុក ក្រុមហ៊ុន ដែលជាអង្គភាពអរូបិយទេ ការទទួលខុសត្រូវព្រហ្មទណ្ឌមែន តែ *មានតែការបង់ពិន័យទេ ជាទោសចម្បង* (មាត្រា ១៦៧) ដែលជាទូទៅ មានចំនួន ច្រើនជាងពិន័យ ចំពោះបុគ្គល។

បន្ថែមពីលើពិនីយ អាចមានទោសបន្ថែម (អាចប្រកាសលុះត្រាចែងដាក់លាក់, ត្រូវតែប្រកាសបើច្បាប់បានចែង មាត្រា ១៦៨ និង ១៦៩)។ ទោសបន្ថែមមានពីស្រាលទៅធ្ងន់ធ្ងរ ដូចជា ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។ លំអិតនៃប្រភេទទោសបន្ថែមនីមួយៗ មានពន្យល់ក្នុងមាត្រា ១៧០ ដល់ ១៨១។ ឧទាហរណ៍មាត្រា ១៧៦ ការបិទគ្រឹះស្ថាន។ ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ ។ ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

មាត្រា ២៧៤ បទដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស

*អំពើដែលដាក់បុគ្គលណាម្នាក់ ដោយរំលោភលើភាពទន់ខ្សោយ ឬលើស្ថានភាពនៃអនិស្សរភាពរបស់បុគ្គលនោះ ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារ ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ត្រូវផ្តន្ទាទោ*

*សដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀលទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។*

**មាត្រា ២៧៧** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

*នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២៧៤ (បទដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៃក្រមនេះ ។*

*នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀលទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ ៖*

*១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ។*

**កំណត់សំគាល់**៖ វាត្រូវមានយន្តការបង្កា ក្នុងវិស័យ ដូចជា វិស័យថ្នាំពេទ្យ អាហារ បរិស្ថាន ព្រោះផលប៉ះពាល់ធ្ងន់ធ្ងរ មិនអាចជួសជុលបាន។ អ្នកវិនិយោគក្នុងវិស័យទាំងនេះ ត្រូវដឹងថាខ្លួននឹងជួបហានីភ័យច្រើន និងធ្ងន់ធ្ងរ ដែលក្នុងករណីខ្លះ មិនអនុញ្ញាតឲ្យដោះសាររួចខ្លួនឡើយ។ ប្រទេសខ្លះ ប្រើ strict liab -ility offence។ ការធ្វើតែទង្វើគឺនាំឲ្យទទួលខុសត្រូវហើយ។ នេះ ខុសពីការទទួលខុសត្រូវព្រហ្មទណ្ឌធម្មតា ព្រោះតម្រូវឲ្យមាន ការបង្ហាញជាតុផ្សំសម្ភារ និងអត្តនោម័ត និងក្នុងករណី មានការដោះសារ ដូចជាការការពារខ្លួនស្របច្បាប់ អាចនាំអ្នកប្រព្រឹត្តមិនទទួលខុសត្រូវព្រហ្មទណ្ឌ។

ដូចនេះ ប្រសិនប់នីតិបុគ្គលបានដឹងអំពីច្បាប់ហើយ សូមប្រយ័ត្នរកស៊ីបានចំណេញ ក៏ប៉ុន្ត កុំប៉ះគេ។ រឿងខ្លះ ផលប៉ះពាល់ មិនអាចស្តារបាន អង្គរក្លាយជាបាយ ដែលអាចនាំឲ្យមានការបិទក្រុមហ៊ុនសងលុយរាប់លានទៀតផង។